# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

**ការិយាល័យចុះឈ្មោះ និង ចាត់តាំងសិស្ស**

440 NORTH BROAD STREET, SUITE 111
PHILADELPHIA, PA 19130

Danielle Seward
*នាយិការង*

ទូរស័ព្ទ៖ ២១៥-៤០០-៤២៩០
ទូរសារ៖ ២១៥-៤០០-៤២៩១


ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៤

ជូនចំពោះ សិស្ស ឬ មាតាបិតា/អាណាព្យាបាល៖

ក្រសួងអប់រំកំពុងទទួលលិខិតដាក់ពាក្យសុំចូលរៀនពីសិស្សានុសិស្សថ្នាក់ទីប្រាំបី ដែលចង់ចូលរៀននៅ វិទ្យាល័យ Kensington និង វិទ្យាល័យថ្មីៗ របស់ក្រសួង តាមវិធីចាប់ឆ្នោត។ ការចាប់ឆ្នោតគឺជាឱកាសសម្រាប់សិស្សានុសិស្សដែលកំពុងរៀនថ្នាក់ទីប្រាំបី ដែលដាក់ពាក្យសុំចូលរៀននៅសាលាដែលមានឈ្មោះដូចខាងក្រោមនេះ សម្រាប់ថ្នាក់ទីប្រាំបួន។ សូមពិនិត្យមើល វិទ្យាល័យ Kensington និង វិទ្យាល័យថ្មីៗ របស់ក្រសួង ដែលមានឈ្មោះនៅក្នុងតារាងខាងក្រោមនេះ ហើយមើលវិបសៃរបស់សាលាទាំងនោះ ដើម្បីស្វែងយល់ថែមទៀតអំពីសាលានីមួយៗ។ យើងខ្ញុំដឹងថា លោកអ្នក ឬ កូនរបស់លោកអ្នក មិនមានឱកាសជ្រើសរើសសាលាទាំងនេះនៅក្នុងវិធីដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យក្នុងពេលថ្មីៗ របស់ពួកគេនេះទេ។ ក្រសួងចង់ធ្វើយ៉ាងណាដើម្បីឲ្យលោកអ្នកដឹងអំពីឱកាសទាំងនេះ។

| ***ឈ្មោះសាលា*** | ***ទីកន្លែង*** |
|---|---|
| *Building 21*<br>*www.b-21.org* | *2000 N. 7th Street, 19122* |
| *Kensington CAPA*<br>*http://kensingtoncapa.wix.com/kcapa* | *1901 N. Front Street, 19122* |
| *Kensington Health Science Academy*<br>*http://www.philasd.org/schools/kensington-health-sciences* | *2495 Emerald Street, 19125* |
| *Kensington International Business, Finance, & Entrepreneurship*<br>*http://philasd.org/schools/kensington-business* | *2501 Coral St, 19125* |
| *Kensington Urban Education*<br>*https://webapps.philasd.org/school_profile/view/5600* | *2051 E. Cumberland Street, 19125* |
| *The LINC High School*<br>*www.the-linc.org* | *122 W. Erie Avenue, 19140* |
| *The U School*<br>*www.uschool.org* | *2000 N. 7th Street, 19122* |

**<u>តើអ្នកណាអាចដាក់ពាក្យសុំចូលរៀនបាន?</u>**

វិទ្យាល័យដែលមានឈ្មោះខាងលើទាំងអស់គឺជាវិទ្យាល័យដែលទទួលសិស្សដោយ «គ្មានលក្ខណវិនិច្ឆ័យ» ហើយគ្មានការតម្រូវចំពោះ ការសិក្សា ឬ អាកប្បកិរិយា សម្រាប់ការទទួលសិស្សទេ។ សិស្សានុសិស្សថ្នាក់ទីប្រាំបីទាំងអស់ អាចដាក់ពាក្យសុំចូលរៀនបាន។ សូមកត់សម្គាល់ថា សិស្សានុសិស្សដែលដាក់ពាក្យសុំចូលរៀននៅ Kensington CAPA គេនឹងតម្រូវឲ្យធ្វើការសម្តែងសាកល្បង សម្រាប់កម្មវិធីសិល្បៈនៅសាលានោះ។

**<u>វិធីដាក់ពាក្យសុំចូលរៀន</u>**

សិស្សានុសិស្សដែលមានចំណាប់អារម្មណ៍ អាចដាក់ពាក្យសុំចូលរៀនតាមអ៊ិនធ័រណិត http://philasd.org/kensington- new_high_schools_lottery។ គេនឹងទទួលលិខិតដាក់ពាក្យសុំចូលរៀនពី ថ្ងៃច័ន្ទ ទី២៤ ខែមិនា រហូតដល់ម៉ោង ៥:០០ ល្ងាច នៃថ្ងៃសុក្រ ទី២៥ ខែមេសា។ គេនឹងជម្រាបទៅក្រុមគ្រួសារ អំពីលទ្ធផលនៃការចាប់ឆ្នោតក្នុងកំឡុងសប្តាហ៍នៃ ថ្ងៃទី៩ ខែមិថុនា។

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា
## ការិយាល័យចុះឈ្មោះ និង ចាត់តាំងសិស្ស
440 NORTH BROAD STREET, SUITE 111
PHILADELPHIA, PA  19130

Danielle Seward
*នាយិការង*

ទូរស័ព្ទ៖ ២១៥-៤០០-៤២៩០
ទូរសារ៖ ២១៥-៤០០-៤២៩១

**<u>ការបើកឲ្យដើរមើលវិទ្យាល័យថ្មីៗរបស់ក្រសួង</u>**

អ្នកដឹកនាំការរៀបចំសាលាមកពី សាលា U (U School), Building 21 និង The LINC នឹងបើកឲ្យដើរមើលសាលា នៅសាលាដែលមានឈ្មោះខាងក្រោមនេះ ដើម្បីណែនាំឲ្យដឹងពី ទស្សនៈ និង គោលបំណង នៃគំរូសាលានីមួយៗ ពន្យល់ពីវិធីចុះឈ្មោះចូលរៀន និងឆ្លើយសំណួររបស់មាតាបិតា និងសិស្សានុសិស្ស។ នឹងមានកុំព្យូទ័រយួរដៃសម្រាប់សិស្សានុសិស្សដែលចង់ដាក់ពាក្យសុំចូលរៀន។

**ថ្ងៃពុធ ទី៩ ខែមេសា**
APM Hall
ម៉ោង ៦ ដល់ ៨ យប់
2319 North 7th Street

**ថ្ងៃសុក្រ ទី១១ ខែមេសា**
Enon Tabernacle Baptist Church
ម៉ោង ៥ ល្ងាច ដល់ ៨ យប់
2800 West Cheltenham Avenue

**<u>ព័ត៌មានបន្ថែម</u>**

ដើម្បីជ្រាបព័ត៌មានថ្មីៗ និង ព័ត៌មានបន្ថែម អំពីការចាប់ឆ្នោតរបស់ វិទ្យាល័យ Kensington និងសាលាថ្មីៗ សូមមើលក្នុងវិបសៃ៖
http://philasd.org/kensington-new_high_schools_lottery។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីវិធីចាប់ឆ្នោត សូមទូរស័ព្ទមក ការិយាល័យចាត់តាំងសិស្ស លេខ ២១៥-៤០០-៤២៩០។ ដើម្បីស្វែងយល់ថែមទៀត អំពី វិទ្យាល័យគំរូថ្មីៗ សូមទូរស័ព្ទមកលេខ ២១៥-៤០០-៤៨៤០ ឬ មើលនៅក្នុងវិបសៃ www.philasd.org/newschoolmodels។

សាលា Kensington ទាំងបួន និង វិទ្យាល័យថ្មីៗ របស់ក្រសួង គឺបង្ហាញពីឱកាសដ៏គួរឲ្យរំភើប សម្រាប់សិស្សានុសិស្សថ្នាក់ទីប្រាំបី នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា។ យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងចំណាយពេលដើម្បីស្វែងយល់ថែមទៀត ហើយចង់ដាក់ពាក្យសុំចូលរៀន។

ដោយសេចក្តីស្ម័គ្រស្មោះ

Danielle N. Seward
នាយិការង ការិយាល័យចុះឈ្មោះ និង ចាត់តាំងសិស្ស

ចម្លងជូនៈ  នាយកសាលា និងអ្នកផ្តល់ឱវាទនៅសាលា